# ក្រុមហ៊ុន អ៊ិន ហ្វុង (ខេមបូឌា) ហ្គាមិនត៍

INFONG ( CAMBODIA ) GARMENT CO.,LTD

អសយដ្ឋាន៖ សួនឧស្សាហកម្មកាណាឌីយ៉ា អគារលេខ6-7 ផ្លូវវេងស្រេង ភូមិត្រពាំងថ្លឹង២ សង្កាត់ចោមចៅ១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ


---

## កំណត់ហេតុកិច្ចប្រជុំ
## ស្តីពី
## ការព្យួរការងារក្នុងក្រុមហ៊ុន អ៊ិន ហ្វុង (ខេមបូឌា) ហ្គាមិនត៍

នៅថ្ងៃទី 01 ខែ 09 ឆ្នាំ 2022 វេលាម៉ោង 02:46 នាទីថ្ងៃរសៀល។ នៅបន្ទប់នាយកក្រុមហ៊ុន បានប្រជុំពិភាក្សាគ្នាអំពីការព្យួរការងារនៅក្នុងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍។ ដែលមានសមាសភាពចូលរួមដូចខាងក្រោម៖

1-ខាងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍។

-Mr. Ma Shunhua នាយកក្រុមហ៊ុន

-Mrs. **ឃួន សុខសាន្ត** ប្រធានរដ្ឋបាល

-Mrs. **ជា មួយជូ** បកប្រែ

2-ខាងតំណាងកម្មករ / តំណាងសហជីព

-Mr.**ឡញ សំ** តំណាងកម្មករ / តំណាងសហជីពសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា(ស៊ីខៅឌូ)

- Mr. **លី តារា** តំណាងសហាម្ព័ន្ធសហជីពកម្មករកម្ពុជា

ក្រោយពីបានពិភាក្សាយ៉ាងល្អិតល្អន់រួចមក ភាគីខាងក្រុមហ៊ុន នឹង ភាគីតំណាងកម្មករ / តំណាងសហជីពបានឯកភាពគ្នាទាក់ទងនឹងការរៀបចំព្យួរការងារដូចខាងក្រោម:

១-សំរេចព្យួរការងាររយះពេល(13ថ្ងៃ)ថ្ងៃធ្វើការ។ គឺចាប់ពីថ្ងៃទី13 ខែ09 ឆ្នាំ2022 ដល់ថ្ងៃទី27 ខែ09 ឆ្នាំ2022 ថ្ងៃទី 28 ខែ09 ឆ្នាំ2022 ចូលធ្វើការធម្មតាវិញ។

២-សំរេចកំឡុងពេល(13ថ្ងៃ) នៃការព្យួរការងារនេះខាងក្រុមហ៊ុនគិតប្រាក់ឈ្នួលអោយ 50%នៃប្រាក់ឈ្នួលគោលរបស់កម្មករនិយោជិក។

៣-នៅថ្ងៃទី 10 ខែ09 ឆ្នាំ2022 ក្រុមហ៊ុនរៀបចំបើកប្រាក់ឈ្នួលដែលនៅសល់សំរាប់ខែ08 ឆ្នាំ2022នឹង បន្ថែមបើកប្រាក់ឈ្នួលសំរាប់ ខែ 09 ឆ្នាំ2022 ចំនួន $60 (ហុកសិបដុល្លា) បន្ថែមពីលើទៀត។

៤-កម្មករនិយោជិកដែលត្រូវព្យួរការងារនៅក្នុងក្រុមហ៊ុន អ៊ិន ហ្វុង(ខេមបូឌា)ហ្គាមិនត៍ មានចំនួនសរុបទាំងអស់ ៥៤៩នាក់ (ប្រាំរយសែសិបប្រាំបួននាក់)។

ចុងបញ្ចប់នៃកិច្ចប្រជុំនេះ លោកនាយកក្រុមហ៊ុនបានថ្លែងអំណរគុណចំពោះអ្នក

ចូលរួមទាំងអស់ ដែលបានចូលរួមពិភាក្សាផ្តល់មតិយោបល់គ្នាទៅវិញទៅមក។

កិច្ចប្រជុំនេះបានបញ្ចប់នៅវេលាម៉ោង 03:55 នាទីថ្ងៃរសៀលថ្ងៃខែឆ្នាំដដែល ។

**អ្នកធ្វើកំណត់ហេតុ**

Mrs. ឃួន សុខសាន្ត
ប្រធានរដ្ឋបាល ក្រុមហ៊ុន

**តំណាងកម្មករ / តំណាងសហជីព**
បានឃើញ និង ឯកភាព

**ប្រធានកិច្ចប្រជុំ**
បានឃើញ និង ឯកភាព

INFONG (CAMBODIA) GARMENT CO., LTD